ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ : ៧៩៥ សរ.១ ប.ស្ថ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃការវាយតម្លៃលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ១៤ នៅក្នុងខេត្តក្រចេះ ឧត្តរមានជ័យ ព្រះវិហារ និងរតនគិរី ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន

ក្រសួងបរិស្ថាន មានកិត្តិយស សូមជម្រាបជូនដល់សាធារណជនឱ្យបានជ្រាបថា យោងតាម ស.ជ.ណ លេខ ៩៥៦ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៥ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចអនុញ្ញាតឱ្យក្រុមហ៊ុន ១២ បន្ថែមទៀត ដែលទទួលបានសិទ្ធិវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន មានផ្ទៃដីសរុប ៤១ ២៤៤ ហិកតា នៅខេត្តក្រចេះ ឧត្តរមានជ័យ ព្រះវិហារ បន្តអនុវត្តគម្រោងនិងបំពេញនីតិវិធីលើផ្ទៃដី ដែលបានដោះស្រាយផលប៉ះពាល់រួច ដោយត្រូវចុះកិច្ចសន្យាឡើងវិញ និងកាត់បន្ថយរយៈពេលនៃការវិនិយោគ ដែលផ្តល់ឱ្យពីមុនមកមាន ៩៩ ឆ្នាំ ៨០ ឆ្នាំ និង៧០ ឆ្នាំ ឱ្យមកនៅត្រឹមរយៈពេល ៥០ ឆ្នាំវិញ។ រីឯក្រុមហ៊ុនចំនួន ២ ទៀត (មានផ្ទៃដីសរុប ១៧ ៩៩៨ ហិកតា) ដែលទទួលសម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបនប្រើប្រាស់ដោយចីរភាពនៃឧទ្យានជាតិវិរជ័យក្នុងខេត្តរតនគិរី ត្រូវបានរាជរដ្ឋាភិបាល អនុញ្ញាតបន្តនីតិវិធីដោយទុករយៈពេល ៦ ខែ ដើម្បីតាមដានវឌ្ឍនភាព និងកែសម្រួលរយៈពេលវិនិយោគពី ៧០ ឆ្នាំមកនៅត្រឹម ៥០ ឆ្នាំវិញ។

ក្រុមហ៊ុនទាំង ១២ ដែលត្រូវបានអនុញ្ញាតឱ្យអនុវត្តគម្រោងនិងបំពេញនីតិវិធីលើផ្ទៃដី ដែលបានដោះស្រាយផលប៉ះពាល់រួច មានទីតាំងស្ថិតនៅក្នុងខេត្តក្រចេះចំនួន ៨ ក្រុមហ៊ុន ទទួលបានសម្បទានដីសេដ្ឋកិច្ចនៅតំបន់ប្រើប្រាស់ដោយចីរភាពនៃដែនជម្រកសត្វព្រៃស្នួល និងក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល នៅខេត្តឧត្តរមានជ័យ និងព្រះវិហារមានចំនួន ៤ ក្រុមហ៊ុនដែលទទួលបានសម្បទានដីសេដ្ឋកិច្ចនៅដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព។

រហូតដល់ពេលនេះ ក្រសួងបរិស្ថាន បានពិនិត្យនិងវាយតម្លៃគម្រោងវិនិយោគអភិវឌ្ឍន៍ទាំងអស់ចំនួនសរុប ១១៣ (ផ្ទៃដីសរុប ៦១០ ២៩៦,៧៥ ហ.ត) ដែលក្នុងនេះគម្រោងចំនួន ៩០ ត្រូវបានដាក់ឆ្លងអង្គប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីពិភាក្សា និងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាល ក្នុងការពិនិត្យ

និងសម្រេច ហើយជាលទ្ធផលគម្រោងរបស់ក្រុមហ៊ុនចំនួន ២៣ (ផ្ទៃដីសរុប ៩០ ៦៨២ ហ.ត) ត្រូវបានរាជរដ្ឋាភិបាលសម្រេចនិរាករណ៍ (ដកហូត) សិទ្ធិវិនិយោគ គម្រោងចំនួន ៤ (ផ្ទៃដីសរុប ៣២ ២៨៧ ហ.ត) ត្រូវបានក្រុមហ៊ុនប្រគល់ដោយស្ម័គ្រចិត្តឱ្យរាជរដ្ឋាភិបាលគ្រប់គ្រងវិញ គម្រោងចំនួន៤ (ផ្ទៃដីសរុប ១៥ ៧៩៩ ហ.ត) ត្រូវបានរាជរដ្ឋាភិបាលកាត់បន្ថយទំហំផ្ទៃដីវិនិយោគ និងគម្រោងចំនួន ២០ (ផ្ទៃដីសរុប ១៣១ ៧១៧,៧៥ ហ.ត) ត្រូវបានរាជរដ្ឋាភិបាលទុកពេលឱ្យពី ៦ ខែ ទៅ ១ ឆ្នាំ ដើម្បីបន្តនីតិវិធី (ស្ថិតក្រោមការតាមដាន) ហើយគម្រោងចំនួន ២៨ (ផ្ទៃដីសរុប១៥១ ៨៩១ ហ.ត) ត្រូវបានរាជរដ្ឋាភិបាលសម្រេចឱ្យបន្តអនុវត្តគម្រោងលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ដោយកាត់បន្ថយរយៈពេលនៃកិច្ចសន្យាមកត្រឹម ៥០ ឆ្នាំ។

ចំណែកគម្រោងចំនួន ១១ ទៀត ដែលមានផ្ទៃដីសរុប ៤៧ ៧៣៦ ហិកតា កំពុងត្រូវបានពិនិត្យ និងសម្រេចដោយគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច។ គម្រោងចំនួន ២៣ ផ្សេងទៀតនឹងត្រូវដាក់ឆ្លងគណៈកម្មការអន្តរក្រសួងក្នុងពេលឆាប់ៗនេះ។ ការត្រួតពិនិត្យវាស់វែង និងវាយតម្លៃគម្រោងសម្បទានដីសេដ្ឋកិច្ចឡើងវិញនេះសំដៅពង្រឹងការគ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍន៍លើដីសម្បទានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថានទាំងនេះឱ្យ កាន់តែមានប្រសិទ្ធភាពបំណងដើម្បីផ្តល់ភាពកក់ក្តៅដល់អ្នកវិនិយោគទុន ក៏ដូចជាដោះស្រាយលើផលប៉ះពាល់ទាំងឡាយឱ្យបានត្រឹមត្រូវ និងកំណត់ច្បាស់ថាសម្បទានដីសេដ្ឋកិច្ចទាំងអស់នឹងមិនមានការប៉ះពាល់ដល់ដីធ្លីរបស់ប្រជាពលរដ្ឋឡើយ។


*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង*

ឯកឧត្តម ស្រ៊ុន ដារិទ្ធិ នាយខុទ្ទកាល័យក្រសួងបរិស្ថាន

ទូរស័ព្ទ៖ ០១២ ៤៤៨ ៤៤៤

អ៊ីម៉ែល៖ srundarith@gmail.com


